ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ០១
ចុះថ្ងៃទី១២ ០១ ២០០៤
សាលដីកា
លេខ : ០៣
ចុះថ្ងៃទី២៦ ០១ ២០០៥

តាងនាមប្រជារាស្ត្រខ្មែរ

# តុលាការកំពូល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៦ ខែមករា ឆ្នាំ ២០០៥
ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ :

១ - ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន
២ - លោក ឃឹម ស៊ីផល ចៅក្រម
៣ - លោក ទេវ៉ុល មួន ចៅក្រម
៤ - លោក សោម សិរីវឌ្ឍ ចៅក្រមរបាយការណ៍
៥ - លោក ប៉ែន សារឿន ចៅក្រម
លោក ឃាង ស្រ៊ុន ក្រឡាបញ្ជី
តំណាងមហាអយ្យការ
លោក ឈួន ចាន់ថា ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ៣២ "ង" ចុះថ្ងៃទី១២ ០៤ ២០០២ របស់ សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ០១ ចុះថ្ងៃទី១២ ០១ ២០០៤របស់ តុលាការកំពូល ។

១ - ជនជាប់ចោទឈ្មោះ ប្លុង ប៊ុនឈួយ ហៅជួយ "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស ជាតិខ្មែរ អាយុ ៤៨ ឆ្នាំ មុខរបរ លក់ថ្នាំពេទ្យ កើតនិងទីលំនៅសព្វថ្ងៃភូមិប៉ូលស្រីក្រោក ក្រុមទី១ ឃុំប៉ូលស្រីក្រោក ស្រុក មង្គលបុរី ខេត្តបន្ទាយមានជ័យ ប្រពន្ធឈ្មោះ ញ៉ិច សុងហ៊ាង មានកូន០២នាក់ ឪពុកឈ្មោះប្លុងកែង ម្តាយឈ្មោះ ពិន ថៃ "ស" ។

- មេធាវី លោក រ៉ាយ ប៊ុនធឿន

២ - ជនជាប់ចោទឈ្មោះរ៉ា ហាន "ចុងបណ្តឹងសាទុក្ខ" ភេទ ប្រុស អាយុ៤១ ឆ្នាំ ជាតិខ្មែរ កើតនិងសព្វថ្ងៃនៅភូមិប៉ូលស្រីក្រោក ឃុំ ប៉ូលស្រីក្រោក ស្រុក មង្គលបុរី ខេត្ត បន្ទាយមានជ័យ ប្រពន្ធឈ្មោះ ប៉ែន ធារី មានកូន០២នាក់ ឪពុកឈ្មោះ ញ៉ក់ រ៉ា "ស" ម្តាយឈ្មោះលួង ល៊ួន "រ" ។

- មេធាវី គ្មាន

- ត្រូវចោទពីបទៈបង្កអគ្គីភ័យ ប្រព្រឹត្តនៅភូមិប៉ូលស្រីក្រោក ឃុំ ប៉ូលស្រីក្រោក ស្រុក មង្គលបុរី ខេត្ត បន្ទាយមានជ័យ កាលពីថ្ងៃទី០១ ០៤ ១៩៩៨ បទល្មើសដែលមានចែងតាមមាត្រា ៥៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ទិន ធាង ប្រាន់ គង់ ស្រូវ ជី ឡូន ចាន់ឌី , ប៉ែន ធារី ភិន សុង យ៉ើហ គង្វីម ស្លួន កក់ ចៅ ប៊ុក វ៉ាង្វម ស៊ូ យ៉ុត ហ៊ាត , ប៉ែន ស៊ីម , គុណ អេង , ចាន់ ប៊ុនធី , ដៅ គុណវ៉ាត់ , ដៅ ប៊ុគុណ , ថៃ ដារី , ខៀវ ពន្ធារី , កាន់ លីហេង , អ៊ុយ វ៉ាន់ , ស៊េង អនុណ , ប៊ុត គឹមស៊ីដ , ផ៊ត លាង , វ៉ា កា , ស្រី ចាន់ឌី , វ៉ា ជីវ , ហុត រិណាត , ខ្លាន់ វ៉ាត់ , សព្វថ្ងៃនៅភូមិឫស្សីក្រោក ឃុំ ឫស្សីក្រោក ស្រុក មង្គលបុរី ខេត្ត បន្ទាយមានជ័យ ជាម្ចាស់បណ្ដឹងសាទុក្ខ តំណាងដោយលោក ខៀវ ទង ។

- មេធាវី គ្មាន

- តាមពាក្យបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ស្លួន តក់ , យើម ប៊ុក ស៊ិត ឌី សុខ វ៉ៃ , ចាន់ ប៊ុនលី , តៅ ណាក់ , ហុក រិណាត ស្រូវ ជី , ស៊េង អនុណ , ខៀវ ពន្ធារី , យ៉ូវ គង្វីម , ភិន ធាង , ខៀវ ទង ជួប វ៉ាច៉ាឌី , ថៃ ដារី , គុណ អេង , វ៉ា ខ្លាំ , វ៉ា កា , យ៉ុត ហ៊ាត , ប៉ែន ធារី , ប៉ែន ស៊ីម , វ៉ាង្វម ប៊ូ , នួន ចាន់ធី , ដៅ គុណវ៉ាត់ , ចាន់ គង់ , វ៉ា ជីវ , កាន់ លីហេង , ដៅប៊ុគុណ , អ៊ុយ វ៉ាន់ , ខ្លាន់ វ៉ាត់ , ចៅ ប៊ុក , ផ៊ត លាង ទាំងអស់គ្នាប្ដឹងពីជនល្មើសដែលបង្កអគ្គីភ័យ បណ្ដាលឱ្យនេះមហន្តរាយដល់ទ្រព្យសម្បត្តិ ដោយហេតុថា កាលពីថ្ងៃទី០៣ ០៤ ១៩៩៨ ម៉ោង១១ថ្ងៃត្រង់មានអគ្គីភ័យមួយកើតឡើង នៅក្នុងផ្សារមង្គលបុរី ខេត្តបន្ទាយមានជ័យ បណ្ដាលអោយខូចខាតទ្រព្យសម្បត្តិអស់ជាច្រើន ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការខេត្តបន្ទាយមានជ័យសំរេច:

១ - មិនចោទប្រកាន់ :

ឈ្មោះប្លង់ ប៊ុនជួយ ភេទ ប្រុស អាយុ ៤៥ ឆ្នាំ នៅភូមិ ឃុំ ឫស្សីក្រោក ស្រុក មង្គលបុរី ខេត្ត បន្ទាយមានជ័យ និង ឈ្មោះ វ៉ា ហាន់ ភេទ ប្រុស អាយុ ៤៨ នៅភូមិ ឃុំ ឫស្សីក្រោក ស្រុក មង្គលបុរី ខេត្ត បន្ទាយមានជ័យ ពីបទៈ បង្កអគ្គីភ័យ ប្រព្រឹត្តកាលពីថ្ងៃទី៣ ០៤ ៩៨ នៅម៉ោង១១ ថ្ងៃត្រង់ នៅភូមិ ឃុំ ឫស្សីក្រោក ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ។

- បានឃើញដីកាលើកលែងចោទប្រកាន់លេខ ២៣ដសក ចុះថ្ងៃទី០៨ ០៣ ១៩៩៩ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារសំរេចដូចតទៅ :

១ - លើកលែងចោទប្រកាន់លើឈ្មោះ ប្លង់ ប៊ុនជួយ ភេទ ប្រុស អាយុ៤៥ ឆ្នាំ ពីបទៈ ថាបានបង្កអគ្គីភ័យ ប្រព្រឹត្តនៅភូមិ ឫស្សីក្រោក ឃុំ ឫស្សីក្រោក ស្រុក មង្គលបុរី ខេត្ត បន្ទាយមានជ័យ កាលពីថ្ងៃទី០៣ ០៤ ៩៨ និងសំរេចដោះលែងឈ្មោះនេះពីមន្ទីរឃុំឃាំង បើជននេះមិនត្រូវឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ ។

- បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០២ ចុះថ្ងៃទី១២ ០១ ២០០០ របស់ប្រជាជនរងគ្រោះទាំង ២៤ នាក់ ប្ដឹងតវ៉ាមិនសុខចិត្តពីដីកាលេខ១៤២ ដសព ចុះថ្ងៃទី០៣ ០៣ ១៩៩៩ របស់អយ្យការអមតុលាការខេត្ត បន្ទាយមានជ័យ ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍សំរេច :

១ - ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១២ ០១ ២០០០ របស់ជនរងគ្រោះទុកជាត្រឹមត្រូវតាម

ទំរង់ច្បាប់ តែបដិសេធចោលដោយផ្អែកនឹងគតិច្បាប់ ។

២ - តំកល់ដីការលើកលែងចោទប្រកាន់លេខ ២៣ ដលក ចុះថ្ងៃទី០៨.០៧.៩៧ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្ត បន្ទាយមានជ័យទុកជាបានការដដែល ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៣២ "ង" ចុះថ្ងៃទី១២ - ០៥ - ២០០២ របស់ សាលាឧទ្ធរណ៍ដែលមានសេចក្តីសំរេចដូចតទៅ :

១ - ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២.០១.២០០០ របស់ដើមបណ្តឹងរដ្ឋប្បវេណី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្អែកនឹងគតិច្បាប់ ។

២ - តំកល់ដីការលើកលែងចោទប្រកាន់លេខ ២៣ដលក ចុះថ្ងៃទី០៧.០៧.១៩៩៧ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្ត បន្ទាយមានជ័យ ទុកជាបានការ ។

៣ - សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខមេធាវីការពារអោយជនជាប់ចោទក្នុងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខតាមបណ្តឹងលេខ ៧១ ចុះថ្ងៃទី១៥.១០.២០០២ របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងតវ៉ាមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ៣២ "ង" ចុះថ្ងៃទី១២.០៥.២០០២ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណារបស់ឈ្មោះមុក វិណាតនិងឈ្មោះលែង អរុណ តំណាងប្រជាពលរដ្ឋទាំង ៣១នាក់ ចុះថ្ងៃទី ២៣ - ០២ - ២០០៥ ។

- បានឃើញសារណាតបរបស់ឈ្មោះ ប្លង់ ប៊ុនឈួយ "ជួយ" ចុះថ្ងៃទី២២.០៣.២០០៥ ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍.

- បានស្តាប់តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋាននាពេលសវនាការថា

១ - បណ្តឹងសាទុក្ខរបស់ជនរងគ្រោះ២៥ នាក់ ធ្វើឡើងក្នុងកំណត់ច្បាប់ សប្បីរ .ក ពិចារណា ។

២ - តំកល់សាលដីកាព្រហ្មទណ្ឌលេខ ៣២ "ង" ចុះថ្ងៃទី១២.០៥.២០០២របស់ សាលាឧទ្ធរណ៍ទុកជាបានការទាំងមូល ។

- បានស្តាប់សាវតាជាតិតំណាងឱ្យប្រជាជន គឺលោកខៀវ ទង និងចម្លើយអះអាង នាពេលសវនាការថា: ការប្តឹងមិនសុខចិត្តរហូតឡើងមកដល់ថ្នាក់លើនេះ ដោយសារតែតុលាការថ្នាក់ក្រោមលើកលែងចោទប្រកាន់ឈ្មោះប្លង់ ប៊ុនឈួយ ពីព្រោះឈ្មោះនេះបានបង្កអគ្គិភ័យចេញពីផ្ទះរបស់គាត់ បណ្តាលអោយឆេះរាលដាលដល់ផ្ទះប្រជាជននៅជិតខាងខ្លោចខ្ទីអស់គ្មានសល់ ។ ការឆេះដែលគេឃើញផ្ទះនោះមានអាំងសាច់គោ ព្រោះវត្ថុចូលឆ្លាចិនផងនោះ ជាពិសេសឈ្មោះប្លង់ ប៊ុនឈួយ ក៏បានសារភាពដូចមានក្នុងកំណត់ហេតុស្រាប់ ។ សូមអង្គសវនាការមេត្តារកយុត្តិធម៌ ព្រោះទ្រព្យសម្បត្តិប្រជាជនដែលឆេះនោះបាត់បង់អស់គ្មានសល់ ហើយគិតជាប្រាក់ក៏ច្រើនដែរ ។

- បានស្តាប់សាវតាជាតិជនជាប់ចោទឈ្មោះវ៉ា ហាវ៉ និងចម្លើយអះអាងនាពេលសវនាការថា: បញ្ហាការឆេះផ្ទះនោះ មិនមែនឆេះចេញពីផ្ទះខ្ញុំបាទទេ ថ្វីត្បិតតែផ្ទះខ្ញុំនៅជាប់ផ្ទះប៊ុនឈួយ

មែន ។ ព្រោះផ្ទះខ្ញុំមិនបានឆេះអាំងនិងធ្វើអ្វីនៅក្នុងចង្ក្រានបាយទេ ប៉ុន្តែពេលដែលភ្លើងឆេះហើយដល់ប្រជាជនភាគច្រើនព្រមទាំងរូបខ្ញុំក៏បានឃើញ ចេញពីផ្ទះ ប៊ុនឈួយ មុនគេបង្អស់ ទើបរាលដាលឆាំងឆាប់ រហ័សបំផុតនៃការឆេះនោះ ក្នុងរដូវប្រាំងនាថ្មីនមានខ្យល់មានអាំងគ្រប់ទិសចេញចំផងនោះ ឆ្ពោះទៅរបស់ប៊ុនឈួយ វិញ គេដឹងថាមានអាំងចៀននំផ្លូកទំព ។ សូមក្រុមប្រឹក្សាអង្គជំនុំជម្រះពិចារណានេះ ជួយនក ក្តីផង ។

– បានស្តាប់មេធាវី លោក ខាយ ប៊ុនធឿន ទៀងសន្និដ្ឋានការពារឱ្យជនជាប់ចោទឈ្មោះ ប្លង់ ប៊ុនឈួយ នាពេលសវនាការថា ខ្ញុំសូមគោរពជូនអង្គសវនាការថា ផ្ទះរបស់ឈ្មោះទ័ា ហាន់ និងផ្ទះកូនក្តីខ្ញុំនេះ គឺនៅជាប់គ្នាត្រង់ចន្លោះដែលផ្សែងដែលចេញមក គឺមិនមែនចំផ្ទះកូនក្តីខ្ញុំនោះទេ ហើយៗ ពីព្រោះនៅរដូវនោះមានក្មេងលេងផាវជុតទំលេងគ្រប់មុខបណ្តាលអោយឆេះ ហើយមានផ្សែងនៅឆ្ងាយពីផ្ទះកូនក្តីខ្ញុំ តែការប្តឹងចោទដាក់បន្ទុកកូនក្តីខ្ញុំ រហូតដល់តុលាការថ្នាក់ក្រោមក៏បានលើកលែងចោទប្រកាន់និងធ្វើការសន្និដ្ឋានគ្មានភស្តុតាងណាមួយថា ភ្លើងនោះចេញពីផ្ទះប៊ុនឈួយ ពិតប្រាកដ ហេតុនេះ សូមមេត្តាតម្កល់សាលដីកាសាលានុទ្ទេសរដ្ឋអាជ្ញាតកការ ។

– បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលបន្ថែមនាពេលសវនាការថា សូមរក្សាការសន្និដ្ឋានរបស់ខ្លួនទុកនៅដដែល ។

– ក្រោយពីបានស្តាប់ចម្លើយការណ៍របស់ចៅក្រមរបាយការណ៍ ។

– ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។

– ក្រោយពីបានស្តាប់ចម្លើយរបស់តំណាងជនរងគ្រោះ ចម្លើយរបស់ជនជាប់ចោទឈ្មោះ ទ័ា ហាន់ និងសេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ ។

– ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុ លា កា រ កំ ពូ ល

– យល់ឃើញថា បណ្តឹងសាទុក្ខលេខ០៧១ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០២ របស់ឈ្មោះ ហុក រិណាត និង សែង អរុណ តំណាងប្រជាជន ២៤ គ្រួសារ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជម្រះបានដោយមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តី ។

– យល់ឃើញថា ពុំមានភស្តុតាងណាដែលបញ្ជាក់ថា អគ្គីភ័យដែលកើតឡើងកាលពីថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៨ នៅភូមិឫស្សីក្រោក ឃុំឫស្សីក្រោក ស្រុក មង្គលបុរី ខេត្ត បន្ទាយមានជ័យ កើតឡើងពីចេតនាដុតបំផ្លាញឬពីអំពើល្មើសណាមួយ ដែលកំណត់និងផ្តន្ទាទោសតាមមាត្រា៥៣ នៃ ច្បាប់ព្រហ្មទណ្ឌអន្តរកាលនោះទេ ។

– យល់ឃើញថា អគ្គីភ័យថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៨ បានបង្កព្រួសនះកម្មដល់ប្រជាជនជាច្រើនរូប ដែលអ្នកទាំងនោះអាចប្តឹងទៅតុលាការរដ្ឋប្បវេណីទាមទារសំណងពីជនដែលបង្កឱ្យ

មានអត្ថិភាពនេះបាន ។

- យល់ឃើញថាជនជាប់ចោទឈ្មោះប្លុង ប៊ុនឈួយ ហៅជួយ បានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះឡើងកំបាំងមុខឈ្មោះនេះ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៣២ "ឯ" ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទឈ្មោះ វ៉ា ហាវ

កំបាំងមុខជនជាប់ចោទ ប្លុង ប៊ុនឈួយ ប៉ុន្តែ

ចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្តឹងសាទុក្ខលេខ ៣១ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០២ របស់ឈ្មោះ ហុក វិណាត និង ស៊ែង ភនុរ៉ា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តំកល់សាលដីកាព្រហ្មទណ្ឌលេខ ៣២ "ឯ" ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ - សាលដីកានេះប្រកាសតាមសវនាការជាសាធារណៈនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៥ ៚